ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា
លេខ :..០៦០០..........ន.ទ.ក.

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងការគ្រប់គ្រងលើការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ទូរគមនាគមន៍គ្រប់ប្រភេទ នៅតាមភូមិសាស្ត្ររាជធានី/ខេត្ត

ដោយអនុលោមតាមព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីទូរគមនាគមន៍ និង អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ខែមីនាឆ្នាំ២០១៦ និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) បាន សង្កេតឃើញថាទោះបីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចេញលិខិតណែនាំ លេខ ១៦៦ បទ ចុះថ្ងៃទី១៦ខែកុម្ភៈឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ក្នុងភូមិសាស្ត្រខេត្ត ជូនចំពោះឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី/ខេត្តទាំង២៥ ដើម្បីស្នើសុំការសហការចាត់វិធានការរឹតបន្តឹង ការផ្តល់លិខិតអនុញ្ញាតសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ក្នុងភូមិសាស្ត្រ ខេត្ត និង និយ័តករទូរគមនាគមន៍កម្ពុជា បានចេញលិខិតលេខ ០៣១១ ប.ក.ទ.ក. ចុះថ្ងៃ ទី២៧ខែកុម្ភៈឆ្នាំ២០១៥ ព្រមទាំងរំលឹកជារឿយៗនៅក្នុងកិច្ចប្រជុំនិយ័តកម្មរវាង ន.ទ.ក. និងបណ្តាប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ទាំងអស់ ដើម្បីណែនាំដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនផ្តល់សេវា ទូរគមនាគមន៍ទាំងអស់ អនុវត្តតាមខ្លឹមសារនៃលិខិតលេខ ១៦៦ បទ ចុះថ្ងៃទី១៦ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ យ៉ាងណាក៏ដោយក៏ ន.ទ.ក. នៅ តែកត់សម្គាល់ឃើញថា៖

សកម្មភាពរបស់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ស្ទើរតែទាំងអស់ ក្នុងការស្ថាបនា ពាយបណ្តាញខ្សែកាប៊្លីគ្រប់ប្រភេទ ដំឡើងស្ថានីយ បង្គោលអង់តែន និងបរិក្ខារទូរគមនា-គមន៍នានា ក្នុងភូមិសាស្ត្រខេត្តដែលជាហេតុបង្កឱ្យមានបាតុភាពមួយចំនួនប៉ះពាល់សន្តិសុខ

សណ្តាប់ និង បរិស្ថានសង្គម ដូចជាសាងសង់ពុំមានលិខិតអនុញ្ញាតពីក្រសួងស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដី សាងសង់ដោយគ្មានស្តង់ដាសំណង់ច្បាស់លាស់ធ្វើឱ្យមានសភាពវៀចវេរ និងពុំបំពាក់ស្លាកសញ្ញាសម្គាល់កម្មសិទ្ធរបស់ម្ចាស់សំណង់ស្របតាមការណែនាំរបស់ ន.ទ.ក. និងស្ថាប័នជំនាញដទៃពាក់ព័ន្ធ ដែលស្តែងចេញពីកង្វះកិច្ចសហការល្អដោយយកចិត្តទុកដាក់ពីសំណាក់ប្រតិបត្តិករជាមួយមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត។

ដើម្បីទប់ស្កាត់នូវបាតុភាពទាំងនេះ និងសំដៅពង្រឹងការគ្រប់គ្រងការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទក្នុងភូមិសាស្ត្រខេត្តឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន ប្រកបដោយសណ្តាប់ធ្នាប់ល្អ ន.ទ.ក. សូមណែនាំដល់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ទាំងអស់ត្រូវទំនាក់ទំនង និងសហការដាច់ខាតជាមួយមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តដែលតាំងស្ថិតនៅក្នុងភូមិសាស្ត្រដែលខ្លួនមានបំណងសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់ខ្លួនគ្រប់ប្រភេទ មុននឹងធ្វើការសាងសង់ជាមុនសិន។ ក្នុងករណី ន.ទ.ក. ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត រកឃើញថាប្រតិបត្តិករណាមួយមិនព្រមអនុវត្តតាម ន.ទ.ក. នឹងដាក់ពាក្យស្នើសុំទៅអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីចាត់វិធានការតាមនីតិវិធីដូចដែលបានបញ្ញត្តិនៃច្បាប់ស្តីពីទូរគមនាគមន៍។

ទទួលបានសេចក្តីណែនាំនេះ សូមប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងអស់ មេត្តាចូលរួមសហការអនុវត្ត ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។/ BR.

ថ្ងៃ សុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៨

**ប្រធាន**

**ចម្លងជូនៈ**

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- រដ្ឋបាលរាជធានី/ខេត្តទាំង២៥
- គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

TELECOMMUNICATION REGULATOR OF CAMBODIA

**ម៉ុង ចរិយា**